# តើការពិនិត្យជំងឺមហារីកគឺជាអ្វី?

## ការពិនិត្យគឺជាផ្នែកសំខាន់មួយនៃការថែរក្សាសុខភាពរបស់អ្នក

ការពិនិត្យជំងឺមហារីក ពាក់ព័ន្ធនឹងការធ្វើតេស្តសាមញ្ញៗដែលរកមើលរោគសញ្ញាដំបូងនៃជម្ងឺមហារីក ឬលក្ខណៈទាំងឡាយដែលបង្កជំងឺមហារីក។ ការធ្វើតេស្តពិនិត្យអាចរកឃើញជំងឺមហារីកមុនពេលដែលអ្នកអាចមើលឃើញ ឬស្ទាបដឹងការផ្លាស់ប្តូរណាមួយនៅក្នុងខ្លួនរបស់អ្នក។ នៅពេលអ្នករកឃើញជំងឺមហារីកបានទាន់ពេល វាកាន់តែងាយស្រួលក្នុងការព្យាបាលដោយជោគជ័យ។

នៅប្រទេសអូស្រ្តាលី មានកម្មវិធីថ្នាក់ជាតិដើម្បីពិនិត្យចំនួន៣។ ទាំងនេះគឺសម្រាប់ជំងឺមហារីកដោះ ពោះវៀន និងមហារីកមាត់ស្បូន។

## ការថតពិនិត្យដោះ



ជំងឺមហារីកដោះ
គឺជាជំងឺមហារីកទូទៅ
បំផុតក្នុងស្រ្តី

- ស្រ្តីអាយុចាប់ពី៥០-៧៤ឆ្នាំ គួរតែទទួលការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្ស (ក៏ត្រូវបានគេហៅដែរថា ការថតមើលដោះដោយប្រើកាំរស្មីអិក្ស) រៀងរាល់២ឆ្នាំម្តង។
- ការពិនិត្យដោះដោយប្រើកាំរស្មីអិក្ស គឺជាវិធីល្អបំផុតក្នុងការរកជំងឺមហារីកដោះ មុនពេលគេអាចមើលឃើញវា ឬស្ទាបដឹងវា។
- វាមានសារៈសំខាន់សម្រាប់ស្រ្តីទាំងអស់អាយុចាប់ពី៥០-៧៤ឆ្នាំ ដើម្បីថតពិនិត្យ ពីព្រោះស្រ្តីភាគច្រើនត្រូវបានគេធ្វើរោគវិនិច្ឆ័យថាមានជំងឺមហារីកដោះ មិនមានប្រវត្តិគ្រួសារនៃជំងឺនេះទេ។
- ការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្សជាមួយ BreastScreen NSW គឺមិន**នគិ**តថ្លៃទេ។ មិនចាំបាច់មានការបញ្ជូនបន្តពីវេជ្ជបណ្ឌិតទេ។

### អ្វីដែលត្រូវធ្វើ៖

- ដើម្បីធ្វើការណាត់ជួប សូមទូរសព្ទទៅលេខ **13 20 50** ឬចូលមើលនៅតាមគេហទំព័រ **book.breastscreen.nsw.gov.au**
- ទូរសព្ទទៅលេខ **13 14 50** ដើម្បីនិយាយជាមួយអ្នកបកប្រែផ្ទាល់មាត់។
- សម្រាប់ព័ត៌មានបន្ថែមជាភាសាផ្សេងទៀត សូមចូលមើលនៅតាមគេហទំព័រ **breastscreen.nsw.gov.au**

## ការពិនិត្យពោះវៀន



ជំងឺមហារីកពោះវៀន៩
ក្នុងចំណោម១០
អាចត្រូវបានព្យាបាលដោយ
ជោគជ័យ ប្រសិនបើរក
ឃើញមុនកាលកំណត់

- បុរស និងស្រ្តីអាយុពី៥០-៧៤ឆ្នាំ ដែលមានប័ណ្ណមេឌីឃែរ ឬប័ណ្ណ Department of Veterans Affairs ត្រូវបានគេផ្ញើកញ្ចប់ពិនិត្យជំងឺមហារីកពោះវៀនដោយ**ឥតគិតថ្លៃ**តាមប្រៃសណីយ៍ រៀងរាល់២ឆ្នាំម្តង។
- ការពិនិត្យជំងឺមហារីកពោះវៀនអាចជួយសង្គ្រោះអាយុជីវិតអ្នក ពីព្រោះវាជាវិធីល្អបំផុតក្នុងការរកឃើញជំងឺមហារីកពោះវៀនទាន់ពេល។
- តេស្តពិនិត្យជំងឺមហារីកពោះវៀនគឺលឿន ហើយសាមញ្ញសម្រាប់ធ្វើនៅតាមផ្ទះរបស់អ្នក។

### អ្វីដែលត្រូវធ្វើ៖

- ប្រើកញ្ចប់ពិនិត្យជំងឺមហារីកពោះវៀនរបស់អ្នក នៅពេលវាមកដល់ផ្ទះតាមប្រៃសណីយ៍។
- ចូលមើលនៅតាមគេហទំព័រ **dothetest.com.au** ដើម្បីពិនិត្យថាតើកញ្ចប់បន្ទាប់របស់អ្នកនឹងត្រូវគេផ្ញើមកអ្នកនៅពេលណា។
- ទូរសព្ទទៅលេខ **1800 627 701** សម្រាប់ការសាកសួរទាំងអស់។
- ទូរសព្ទទៅលេខ **13 14 50** ដើម្បីនិយាយជាមួយអ្នកបកប្រែផ្ទាល់មាត់។
- សម្រាប់ព័ត៌មានបន្ថែមជាភាសាផ្សេងទៀត សូមចូលមើលនៅតាមគេហទំព័រ **health.gov.au/resources/translated**

## ការពិនិត្យមាត់ស្បូន



ការពិនិត្យមាត់ស្បូនអាច
បង្ការជំងឺមហារីក
មាត់ស្បូន

- ស្រ្តីអាយុ២៥-៧៤ឆ្នាំ គួរតែពិនិត្យមាត់ស្បូនរៀងរាល់៥ឆ្នាំម្តង។
- អ្នកអាចកក់ទុកការណាត់ជួបមួយ សម្រាប់ការធ្វើតេស្តពិនិត្យមាត់ស្បូនជាមួយវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់អ្នក។
- វេជ្ជបណ្ឌិតខ្លះផ្តល់ជូនការធ្វើតេស្តនេះដោយ**ឥតគិតថ្លៃ**។ អ្នកអាចសួរអំពីតម្លៃនៅពេលអ្នកកក់ទុកការណាត់ជួប។
- ជំងឺមហារីកមាត់ស្បូន អាចត្រូវបានបង្ការដោយការធ្វើតេស្តពិនិត្យមាត់ស្បូន។ នេះដោយព្រោះតែវាស្វែងរកមេរោគមួយហៅថា human papillomavirus (HPV) ដែលបណ្តាលឱ្យកើតជំងឺមហារីកមាត់ស្បូន។

### អ្វីដែលត្រូវធ្វើ៖

- ទូរសព្ទទៅលេខ **1800 627 701** ដើម្បីពិនិត្យមើលថាតើនៅពេលណាដែលអ្នកដល់ពេល សម្រាប់ការធ្វើតេស្តពិនិត្យមាត់ស្បូន។
- កក់ទុកការណាត់ជួបមួយជាមួយវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាក។ អ្នកអាចស្នើសុំវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកជាស្រ្តីភេទដើម្បីធ្វើតេស្ត។
- ទូរសព្ទទៅលេខ **13 14 50** ដើម្បីនិយាយជាមួយអ្នកបកប្រែផ្ទាល់មាត់។
- សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលនៅតាមគេហទំព័រ **cancer.nsw.gov.au/cervical** ឬ **cancerscreening.gov.au/cervical**

**Cancer Institute NSW** | cancer.nsw.gov.au

t +61 (0)2 8374 5600  f +61 (0)2 8374 3600  e information@cancer.nsw.gov.au

SHPN: (CI) 220337-12  CI-0094-05.22 © Cancer Institute NSW 2022